# សីលានៃព្រះប្រោសលោះរបស់យើង

*អែលឌើរ រីលេហ្វត ដបុលយូ អាន់ឌើរសិន*
*នៃពួកចិតសិបនាក់*

ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានទៅទស្សនាទីក្រុងណៅវ៉ូ រដ្ឋអិលលីណោយ ជាមួយនឹងក្រុមគ្រួសាររបស់ខ្ញុំ។ នៅទីនោះ ពួកបរិសុទ្ធជំនាន់ដើមបានមកស្វែងរកកន្លែងរស់នៅ។ មានមនុស្សជាច្រើនបានបាត់បង់គេហដ្ឋានរបស់ពួកគេ និងកសិដ្ឋានរបស់ពួកគេ ហើយអ្នកខ្លះទៀតបានបាត់បង់មនុស្សជាទី ស្រឡាញ់របស់ពួកគេដោយសារការធ្វើទុក្ខបុកម្នេញ យ៉ាងខ្លាំងក្លា។ នៅក្នុងទីក្រុង ណៅវ៉ូ ពួកគេបានប្រមូលផ្តុំគ្នាហើយបានសាងសង់ទីក្រុងថ្មី និងស្រស់ស្អាត។ ប៉ុន្តែការបៀតបៀនឥតមានស្រាកស្រាន្តឡើយ ហើយនៅត្រឹមឆ្នាំ 1846 ពួកគេ ត្រូវបា នបង្ខំឲ្យចាកចេញពីគេហដ្ឋានរបស់ពួកគេសារជាថ្មីម្តង ទៀត--- ពេលនេះគឺស្ថិតនៅកណ្តាលរដូវរងារដ៏ត្រជាក់។ ពួកគេបានរៀបចំរទេះរបស់ពួកគេជាជួរនៅលើផ្លូវផាលី រង់ចាំដល់វេនរបស់ពួកគេដើម្បីឆ្លងកាត់ទឹកដ៏ត្រជាក់នៃទន្លេមិសស៊ីស៊ីពី ទៅកាន់អនាគតដែលមិនដឹង។ នៅពេលពួកយើងឈរនៅលើផ្លូវផាលី នឹកគិតអំពីស្ថានភាពអស់សង្ឃឹមរបស់ពួកគេ កែវភ្នែករបស់ខ្ញុំបាននាំទៅស្លាកសញ្ញាឈើមួយជួរ ដែលដំដែកគោលជាប់នឹងរបង ដែលបានឆ្លាក់ពាក្យដកស្រង់មកពីកំណត់ហេតុរបស់ពួកបរិសុទ្ធ ដែលរងទុក្ខទាំងនេះ។ នៅពេលយើងអានពាក្យដកស្រង់ទាំងនេះ យើងមានភាពអស្ចារ្យចំពោះអ្វីដែលយើងបានរកឃើញ នៅក្នុងពាក្យសំដីរបស់ពួកគេថា មិនអស់សង្ឃឹម និងមិនបាក់ទឹកចិត្ត ប៉ុន្តែមានទំនុកចិត្ត និងការប្តេជ្ញាចិត្ត ហើយរីករាយ។ ពួកគេមានពោរពេញទៅដោយសេចក្តីសង្ឃឹម ជាសេចក្តីសង្ឃឹមដែលត្រូវបានឆ្លុះបញ្ចាំងដោយពាក្យដកស្រង់ទាំងនេះ មកពីកំណត់ហេតុរបស់សារ៉ាដេអាម៉ុន រិចខៃ កុម្ភៈ ឆ្នាំ 1846 បានដកស្រង់ថា៖ «ដើម្បីចាប់ផ្តើមធ្វើដំណើរនៅក្នុងរដូវរងារត្រជាក់ដូច្នេះ... ហាក់ដូចជាកំពុងដើរនៅក្នុងចង្កូមនៃសេចក្តីស្លាប់ ប៉ុន្តែយើងមានសេចក្តីជំនឿ.. (ហើយ) យើងមានអារម្មណ៍ថាត្រូវរីករាយ ដែលថ្ងៃនៃការរំដោះរបស់យើងនឹងមកដល់»។1 ពួកបរិសុទ្ធជំនាន់ដើមទាំងនេះទោះជាគ្មានផ្ទះសម្បែងក្តី ប៉ុន្តែពួកគេមិនអស់សង្ឃឹមឡើយ។ ដួងចិត្តរបស់ពួកគេខ្ទេចខ្ទាំ ប៉ុន្តែវិញ្ញាណរបស់ពួកគេរឹងមាំ។ ពួកគេបានរៀនមេរៀនដ៏បំផុសគំនិត និងសំខាន់មួយ។ ពួកគេបានរៀនថា សេចក្តីសង្ឃឹមដែលមានជាមួយនឹងពរជ័យនៃសេចក្តីសុខសាន្ត និងសេចក្តីអំណរ មិនពឹងអាស្រ័យទៅលើស្ថានភាពទាំងឡាយនោះទេ។ ពួកគេបានរកឃើញថា ប្រភពពិតនៃសេចក្តីសង្ឃឹមគឺជាសេចក្តីជំនឿ- ជាសេចក្តីជំនឿទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ និងទៅលើដង្វាយធួនដ៏អស់កល្បជានិច្ចរបស់ទ្រង់ជាគ្រឹះពិតមួយ ដែលស្ថាបនាជីវិតរស់នៅរបស់យើង។

នៅសព្វថ្ងៃនេះ មានក្រុមអ្នកត្រួសត្រាយផ្លូវផ្សេងទៀតបង្ហាញអំពីគោលការណ៍សំខាន់នេះ។ នៅថ្ងៃអង្គារទី 12 ខែ មករា មានការរំជួយដីដ៏ធំមួយ បានវាយប្រហារលើប្រទេសហៃទី។ ការរញ្ជួយដី បានបន្សល់ទុកនូវការខូចខាតយ៉ាងធ្ងន់ធ្ងរដល់រដ្ឋធានីរបស់ទីក្រុងផតអូព្រីនស៍។ ឥទ្ធិពលរបស់ការរញ្ជួយដីនេះ បានបង្ខិនបង្ខោច--- ដល់មនុស្សប្រហែលជា 1,000,000 នាក់ ឱ្យគ្មានផ្ទះសម្បែង ហើយមានមនុស្ស 200,000 នាក់

ទៀតត្រូវបានរាយការណ៍មកថាបានបាត់បង់ជីវិត។

ខណៈដែលពិភពលោក បានធ្វើតាមការឆ្លើយតបជាអន្តរជាតិ ដែលមិនធ្លាប់មានពីមុន នោះមានការជួយសង្គ្រោះដ៏បំផុសគំនិត និងអស្ចារ្យដទៃទៀត មាននៅក្រោមផ្លូវនៅក្នុងទីក្រុងផតអូព្រីនស៍--- ការណ៍មួយនេះ ដឹកនាំដោយគណៈកម្មការមួយក្រុម ដែលបានបង្កើតឡើងដោយពួកអ្នកដឹកនាំសាសនាចក្រក្នុងតំបន់ហៃទី ដែលបានរៀបចំស្របទៅតាមគំរូបព្វជិតភាព និងប្រតិបត្តិការក្រោមការបំផុសគំនិត។ [រូបភាព #1] សមាជិកនៅក្នុងគណៈកម្មការ នៅក្នុងចំណោមអ្នកដទៃទៀត រួមមាន ប្រធានស្តេកពីររូប និងប្រធានសមាគមសង្គ្រោះស្តេកពីររូប នៅទីក្រុង ផតអូព្រីនស៍ និងប្រធានបេសកកម្ម ដែលមានអាយុ 30 ឆ្នាំ ធ្វើជាអធិបតីលើអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងជាង 74 នាក់នៅក្នុងបេសកកម្មហៃទីផតអូព្រីនស៍ ។ អ្នកផ្សព្វផ្សាយសាសនាទាំងអស់របស់គាត់ គឺជាជនជាតិហៃទី ហើយវាជាអព្ភូតហេតុណាស់ ដែលគ្មានអ្នកផ្សព្វផ្សាយសាសនាណាម្នាក់ ត្រូវបានរងគ្រោះថ្នាក់នៅក្នុងរញ្ជួយដីដ៏បង្ខិនបង្ខោចនេះទេ។ នៅក្នុងដៃរបស់អ្នកដឹកនាំដ៏បំផុសគំនិតក្នុងតំបន់ទាំងនេះ ត្រូវដាក់នូវធនធានរបស់សាសនាចក្រ ជាធនធានដែលរួមមាននូវការបរិច្ចាគដោយសប្បុរសរបស់អ្នករាល់គ្នាជាច្រើន។ ប្រជាជនហៃទីមានអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការបរិច្ចាគទាំងនេះ។ នៅក្រោមការដឹកនាំរបស់គណៈកម្មការ ឡានដឹកស្បៀងពីសាធារណៈរដ្ឋដូមីនីគែន បានមកដល់យ៉ាងឆាប់បំផុត។ នៅក្នុងចន្លោះប៉ុន្មានថ្ងៃនៃការរញ្ជួយដី យន្តហោះបានដឹកម្ហូបអាហារ ប្រព័ន្ធចំរោះទឹកសុទ្ធ តង់ ភួយ សម្ភារថ្នាំពេទ្យ និងក្រុមវេជ្ជបណ្ឌិតមកដល់ទីកន្លែង។

សាលាជំនុំចំនួនប្រាំបួនដែលនៅក្នុងទីក្រុងផតអូព្រីនស៍ និងជុំវិញទីក្រុងនេះ ស្ទើរតែគ្មានការខូចខាតអ្វីសោះ--- នេះជាអព្ភូតហេតុដ៏អស្ចារ្យមួយទៀត។ អំឡុងសប្តាហ៍បន្ទាប់ពីការរញ្ជួយដី សាលាជំនុំទាំងនោះបានក្លាយជាទីជម្រកសំរាប់ប្រជាជនហៃទីជាង 5,000 នាក់ ហើយ ពឹងអាស្រ័យទៅលើម្ហូបអាហារ ទឹក និងការយកចិត្តទុកដាក់ខាងពេទ្យត្រូវបានផ្តល់ឱ្យ។ សេចក្តីត្រូវការសំខាន់ៗត្រូវបានបំពេញ ហើយចាប់ផ្តើមដើបចេញពី ភាពវឹកវរ។

ថ្វីត្បិតតែពួកបរិសុទ្ធហៃទីស្មោះត្រង់បានរងទុក្ខយ៉ាងធំធេងក្តី ក៏ពួកគេពោរពេញទៅដោយសេចក្តីសង្ឃឹមសម្រាប់ពេលអនាគតដែរ។ ដូចជាពួកបរិសុទ្ធកាលពីដើមនៅក្នុងឆ្នាំ 1846 ផងដែរ ដួងចិត្តរបស់ពួកគាត់ត្រូវបានខ្ទេចខ្ទាំ ប៉ុន្តែវិញ្ញាណរបស់ពួកគាត់រឹងមាំ។ ពួកគាត់ក៏កំពុងតែបង្រៀនដល់យើងថា សេចក្តីសង្ឃឹមសុភមង្គល និងសេចក្តីអំណរមិនមែនជាផលិតផលនៃស្ថានភាពនោះទេ ប៉ុន្តែជាផលិតផលនៃសេចក្តីជំនឿទៅលើព្រះអម្ចាស់។

ព្យាការីមរមន ផ្ទាល់មិនចម្លែកចិត្តនឹងស្ថានភាពពិបាកៗទាំងឡាយនោះទេ តែគាត់យល់ និងបង្រៀនយ៉ាងច្បាស់អំពីគោលលទ្ធិនេះ៖

«ហើយម៉្យាងទៀត ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នាអំពីសេចក្តីសង្ឃឹម... មើលចុះខ្ញុំសូមប្រាប់អ្នកថា អ្នករាល់គ្នានឹងមានសេចក្តីសង្ឃឹម ដោយតាមរយៈដង្វាយធួននៃ

ព្រះគ្រីស្ទ... ហើយនេះក៏មកពីសេចក្ដីជំនឿរបស់អ្នកដល់ទ្រង់ ស្របតាមពាក្យសន្យា។ ហេតុដូច្នោះហើយ បើសិនជាមនុស្សណាមួយមានសេចក្ដីជំនឿ នោះគេត្រូវតែមានសេចក្ដីសង្ឃឹម ត្បិតអត់ពីសេចក្ដីជំនឿទៅ នោះពុំអាចមានសេចក្ដីសង្ឃឹមឡើយ»។ 2

សេចក្ដីសង្ឃឹមកើតចេញមកពីសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ។ ទ្រង់បានយកឈ្នះលើលោកិយនេះរួចទៅហើយ ហើយបានសន្យាថា ទ្រង់នឹងជូតទឹកភ្នែករបស់យើង 3 បើសិនជាយើងនឹងងាកបែរទៅរកទ្រង់តែមួយអង្គ ហើយជឿ និងធ្វើតាមនោះ។

មនុស្សមួយចំនួនដែលស្ថិតនៅក្នុងខណៈពេលនេះ មានអារម្មណ៍អស់សង្ឃឹម ឬបាក់ទឹកចិត្ត អាចនឹងងឿងឆ្ងល់ថា តើពួកគេអាចទទួលបានសេចក្ដីសង្ឃឹមមកវិញបានដោយរបៀបណា។ បើសិនជាអ្នកគឺជាមនុស្សម្នាក់ នៃមនុស្សទាំងឡាយនោះ សូមចងចាំថា សេចក្ដីសង្ឃឹម កើតចេញមកជាលទ្ធផលនៃសេចក្ដីជំនឿ។ បើសិនជាយើងនឹងស្ដាបនាសេចក្ដីសង្ឃឹមរបស់យើង នោះយើងត្រូវតែស្ដាបនាសេចក្ដីជំនឿរបស់យើងសិន។

សេចក្ដីជំនឿទៅលើព្រះអង្គសង្គ្រោះ តំរូវឱ្យមានច្រើនជាងការជឿ។ សាវក យ៉ាកុប បានបង្រៀនថា ទោះទាំងអារក្សក៏ជឿដូច្នោះ ព្រះទាំងព្រឺខ្លាចដែរ។ 4 ប៉ុន្តែសេចក្ដីជំនឿពិត តំរូវឱ្យធ្វើការ។ ភាពខុសគ្នារវាងអារក្ស និងសមាជិកស្មោះត្រង់នៃសាសនាចក្រនេះ គឺការមិនជឿ--- ប៉ុន្តែធ្វើការ។ សេចក្ដីជំនឿរីកចំរើនតាមរយៈការគោរពតាមព្រះបញ្ញត្តិទាំងឡាយ។ យើងត្រូវតែធ្វើការនៅក្នុងការរក្សាព្រះបញ្ញត្តិទាំងឡាយ។ ចេញមកពីការណែនាំទៅកាន់ព្រះគម្ពីរ យើងអានថា៖ «អព្ភូតហេតុ មិនបានផលិតសេចក្ដីជំនឿទេ ប៉ុន្តែសេចក្ដីជំនឿរឹងមាំ ត្រូវបានអភិវឌ្ឍដោយការប្រតិបត្តិ ចំពោះដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ ជាពាក្យម៉្យាងទៀត សេចក្ដីជំនឿកើតចេញមកដោយសេចក្ដីសុចរិត»។ 5

នៅពេលយើងព្យាយាមរក្សាព្រះបញ្ញត្តិទាំងឡាយនៃព្រះ ប្រែចិត្តពីអំពើបាបរបស់យើង ហើយសន្យាដោយអស់ពីសមត្ថភាពរបស់យើងដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ យើងចាប់ផ្ដើមរីកចំរើនទំនុកចិត្តថា តាមរយៈដង្វាយធួន នោះអ្វីៗគ្រប់យ៉ាងនឹងមិនអីទេ។ អារម្មណ៍ទាំងនោះ ត្រូវបានបញ្ជាក់ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលដកយើងចេញពីអ្វី ដែលម្ដាយឪពុកអ្នកត្រួសត្រាយផ្លូវរបស់យើង ហៅថា «កំចាត់ចោលកង្វល់»។ 6 ដោយមិនគិតអំពីការសាកល្បងរបស់យើង នោះយើងត្រូវបានបំពេញទៅដោយអារម្មណ៍នៃសុខុមាលភាព និងអារម្មណ៍ដើម្បីច្រៀងជាមួយពួកគេដោយអស់ពីដួងចិត្តថា «ស្រួលទាំងអស់»។ 7

ខ្ញុំមិនមានបំណងចង់កាត់បន្ថយភាពពិតនៃភាពអស់សង្ឃឹមឱ្យនៅកំរិតតិចបំផុតនោះទេ។ សម្រាប់មនុស្សមួយចំនួន ដំណោះស្រាយចំពោះភាពអស់សង្ឃឹម និងកង្វល់ទាំងឡាយ នឹងត្រូវបានរកឃើញតាមរយៈការពិគ្រោះជាមួយនឹងអ្នកជំនាញវិជ្ជាជីវៈដ៏មានសមត្ថភាព។ ប៉ុន្តែយើងភាគច្រើនបំផុត ភាពសោកសៅ និងភាពភ័យខ្លាច ចាប់ផ្ដើមរលាយបាត់ទៅ ហើយត្រូវបានជំនួយដោយសុភមង្គល និងសេចក្ដីសុខសាន្ត នៅពេលយើងដាក់ទំនុកចិត្តរបស់យើងទៅលើអ្នកនិពន្ធ នៃផែនការនៃសុភមង្គល និងនៅពេលយើងអភិវឌ្ឍ

សេចក្តីជំនឿទៅលើម្ចាស់នៃមេត្រីភាព។

ពេលថ្មីៗនេះ មិត្តជាទីស្រឡាញ់ម្នាក់របស់ខ្ញុំ បានទទួលមរណភាពទៅដោយសារជម្ងឺមហារីក។ គាត់ និង គ្រួសាររបស់គាត់ គឺជាមនុស្សដែលមានសេចក្តីជំនឿដ៏មហិមា។ វាគឺជាការបំផុសគំនិតដែលមើលឃើញថា សេចក្តីជំនឿរបស់ពួកគេ បាននាំពួកគេឆ្លងកាត់ពេលដ៏លំបាកនេះដោយរបៀបណានោះ។ ពួកគេបានពោរពេញទៅដោយសេចក្តីសុខសាន្តនៅក្នុងចិត្តដែលគាំទ្រ និងពង្រឹងដល់ពួកគេ។ ដោយមានការអនុញ្ញាតពីពួកគេ ខ្ញុំចង់អានសំបុត្ររបស់សមាជិកគ្រួសារម្នាក់ ដែលបានសរសេរនៅប៉ុន្មានថ្ងៃមុន ដែលឪពុករបស់នាងបានទទួលមរណភាពថា៖

«កាលពីប៉ុន្មានថ្ងៃកន្លងទៅ មានការលំបាកជាពិសេស... កាលពីយប់មិញ នៅពេលយើងបានប្រមូលផ្តុំគ្នានៅជិតគ្រែរបស់លោកប៉ា នោះព្រះវិញ្ញាណនៃព្រះអម្ចាស់ បានធ្វើឱ្យពួកយើងដឹង ហើយបានដើរតួជាអង្គលួងលោមដល់យើងយ៉ាងច្បាស់។ យើងបានទទួលភាពសុខសាន្ត... វាគឺជារឿងដ៏លំបាកបំផុត ដែលយើងគ្រប់គ្នាធ្លាប់បានទទួលបទពិសោធន៍ ប៉ុន្តែយើងទទួលអារម្មណ៍សុខសាន្តនៅក្នុងចំណេះដឹងថា... ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើងបានសន្យា យើងនឹងរស់នៅជាមួយគ្នាជាក្រុមគ្រួសារម្តងទៀត។ បន្ទាប់ពីវេជ្ជបណ្ឌិតបានប្រាប់លោកប៉ានៅក្នុងមន្ទីរពេទ្យថា គ្មានអ្វីដែលត្រូវធ្វើទៀតទេ នោះគាត់បានមើលមកយើងទាំងអស់គ្នាដោយសេចក្តីជំនឿដ៏ឥតខ្ចោះ ហើយបានសួរដោយក្លាហានថា តើមាននរណាម្នាក់នៅក្នុងបន្ទប់នេះមានបញ្ហាជាមួយនឹងផែនការនៃសេចក្តីសង្គ្រោះទេ? យើងគ្មានទេ ហើយមានអំណរគុណចំពោះឪពុក និងម្តាយ ដែលបានបង្រៀនដល់យើងឱ្យមានសេចក្តីទុកចិត្តដ៏ឥតខ្ចោះ ទៅលើផែនការ»។

ខ្ញុំនិយាយទៅកាន់អ្នកដែលរងទុក្ខ អ្នកទួញសោកទាំងអស់ និងអ្នកទាំងឡាយណាដែលឥឡូវនេះប្រឈមមុខ ឬដែលនឹងប្រឈមមុខនឹងការសាកល្បង និងឧបសគ្គទាំងឡាយនៅក្នុងជីវិតនេះ។ សារលិខិតរបស់ខ្ញុំគឺនិយាយទៅកាន់អ្នកទាំងអស់ណា ដែលមានទុក្ខព្រួយ ឬភ័យខ្លាច ឬបាក់ទឹកចិត្ត។ សារលិខិតរបស់ខ្ញុំមានសូវរំពង--- ជាការរំលឹកមួយអំពីការប្រឹក្សាដ៏លួងលោមចិត្តដ៏ខ្ជាប់ខ្ជួន មកពីព្រះវរបិតាជាទីស្រឡាញ់ទៅកាន់កូនចៅរបស់ទ្រង់ ចាប់តាំងពីពិភពលោកបានចាប់ផ្តើម។

«...ចូរចងចាំចុះ ចូរចងចាំចុះថា គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើង គឺព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដែលកូនត្រូវសង់គ្រឹះរបស់កូន ដើម្បីកាលណាអារក្សបញ្ចោញខ្យល់ដ៏ខ្លាំងក្លារបស់វាមក មែនហើយព្រួញរបស់វានៅក្នុងខ្យល់គួច មែនហើយ កាលណាព្រិល និងខ្យល់ព្យុះកំណាចទាំងអស់របស់វាបោកបក់មកលើកូន នោះវានឹងគ្មានអំណាចមកលើកូនឡើយ ដើម្បីទាញកូនចុះទៅក្នុងជង្ហុកនៃសេចក្តីវេទនា និងទុក្ខលំបាកមិនចេះមិនចប់មិនចេះហើយ ពីព្រោះមកពីសីលាដែលកូនបានសង់នៅលើនោះ ដែលជាគ្រឹះដ៏ខ្ជាប់ខ្ជួនមួយ ជាគ្រឹះមួយបើសិនណា មនុស្សសង់នៅលើនោះ នោះពួកគេមិនអាចរលំបានឡើយ»។8

ខ្ញុំថ្លែងទីបន្ទាល់អំពីទ្រង់ ថាទ្រង់បានយកឈ្នះលើលោកិយ ថាទ្រង់នឹងមិនដែលភ្លេច ឬបោះបង់យើង

ចោលឡើយ ត្បិតទ្រង់បានចារិកយើងនៅផ្ទៃបាតដៃរបស់ទ្រង់ហើយ។ 9 ខ្ញុំថ្លែងទីបន្ទាល់ថា អ្នកទាំងឡាយដែលរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នឹងរីកចំរើនសេចក្តីជំនឿ និងសេចក្តីសង្ឃឹម។ ពួកគេនឹងផ្តល់ឱ្យនូវកម្លាំង ដើម្បីយកឈ្នះលើការសាកល្បងទាំងអស់នៅក្នុងជីវិត។ ពួកគេនឹងទទួលបទពិសោធន៍នៃសេចក្តីសុខសាន្ត ដែលហួសលើសពីអស់ទាំងការយល់ដឹង។ 10

នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. Remembrances of Sarah DeArmon Pea Rich, The Iowa Trail, ទំព័រ 173--4។
2. មរ៉ូណៃ 7:40--42។
3. វិវរណៈ 7:17។
4. យ៉ាកុប 2:19។
5. Bible Dictionary, និយមន័យនៃពាក្យសេចក្តីជំនឿ។
6. «មក មកពួកបរិសុទ្ធ» *ទំនុកដំកើង* លេខ 3។
7. «មក មកពួកបរិសុទ្ធ» *ទំនុកដំកើង* លេខ 3។
8. ហេលេមិន 5:12។
9. នីហ្វៃទី 1 21:16។
10. ភីលីព 4:7។